ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
លេខ:..០០១..ស.ជ.ណ...ក.ជ.អ.ច.

# សេចក្តីណែនាំ
## ស្តីពីការរៀបចំប្រារព្ធទិវាជីវៈចម្រុះអន្តរជាតិ ២២ ឧសភា ឆ្នាំ២០១៨

**«ទិវាជីវៈចម្រុះអន្តរជាតិ ២២ ឧសភា»** ត្រូវបានបង្កើតឡើងស្របពេលដែលអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ ចូលជាធរមានក្នុងឆ្នាំ១៩៩៣ ហើយត្រូវបានប្រកាសដាក់ឱ្យប្រារព្ធជាផ្លូវការ នៅទូទាំងពិភពលោកដោយអង្គការសហប្រជាជាតិ ក្នុងឆ្នាំ២០០០ ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីគុណតម្លៃនៃធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី។

ដោយយល់ឃើញអំពីភាពចាំបាច់ និងសារប្រយោជន៍នៃការថែរក្សា និងការពារធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការជួយទ្រទ្រង់ដល់ខឿនសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន ព្រមទាំងផ្តល់នូវសារប្រយោជន៍ជាច្រើនទៀត ដូចជាការទប់ស្កាត់ការប្រែប្រួលអាកាសធាតុ ការផ្តល់ប្រភពថាមពល ទីជម្រកសត្វគ្រប់ប្រភេទ ចំណីអាហារប្រចាំថ្ងៃ និងផលិតកម្មផ្សេងៗ ទើបរាជរដ្ឋាភិបាលកម្ពុជាបានចូលជាសមាជិកអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ (UN-CBD) ក្នុងឆ្នាំ១៩៩៥ ក្នុងគោលដៅចូលរួមចំណែកជាមួយពិភពលោកធានាឱ្យបាននូវការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានជីវៈចម្រុះប្រកបដោយនិរន្តរភាព និងការបែងចែកផលប្រយោជន៍ទទួលបានពីការប្រើប្រាស់ធនធានពន្ធុប្រកបដោយសមធម៌។ ជាក់ស្តែង ចាប់តាំងពីឆ្នាំ២០១០មក កម្ពុជាបានចាប់ផ្តើមប្រារព្ធ **«ទិវាជីវៈចម្រុះអន្តរជាតិ ២២ ឧសភា»** ដោយបានរៀបចំយុទ្ធនាការ ក្នុងរូបភាពជា មីទ្ទិញ ព្រឹត្តិការណ៍មហាជន វេទិកាតុមូល ការតាំងពិព័រណ៍ និងល្បែងល្បងប្រាជ្ញា ដើម្បីបញ្ជ្រាបការយល់ដឹងអំពីជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីដល់ស្រទាប់មហាជនគ្រប់មជ្ឈដ្ឋាន ស្របតាមជម្រើសប្រធានបទនៃឆ្នាំនីមួយៗ។

ដើម្បីធានានិរន្តរភាព និងប្រសិទ្ធភាពនៃការរៀបចំប្រារព្ធ **«ទិវាជីវៈចម្រុះអន្តរជាតិ ២២ ឧសភា»** ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព សូមដាក់ចេញនូវគោលការណ៍សម្រាប់ការអនុវត្តដូចខាងក្រោម៖

១. អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវ៖
- រៀបចំឯកសារ កម្មវិធី និងផ្សព្វផ្សាយអំពីសារសំខាន់នៃការរៀបចំ **«ទិវាជីវៈចម្រុះអន្តរជាតិ ២២ ឧសភា»** នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨
- សហការឱ្យបានជិតស្និទ្ធជាមួយក្រសួងបរិស្ថាន ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពក្រោមឱវាទ មន្ទីររាជធានី-ខេត្ត និងអ្នកពាក់ព័ន្ធ ក្នុងការអនុវត្តរៀបចំប្រារព្ធទិវាជីវៈចម្រុះតាមគ្រប់រូបភាព និងមធ្យោបាយ។



អគារមរតកតេជោ ដីឡូតិ៍លេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ (៨៥៥) ៨៥ ២១៨ ៣៨០

២. រដ្ឋបាលថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន វិស័យឯកជន និងអ្នកពាក់ព័ន្ធត្រូវៈ

- ចូលរួម និងសហការឱ្យបានជិតស្និទ្ធជាមួយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព តាមរយៈមន្ទីរបរិស្ថានរាជធានី-ខេត្ត ដើម្បីទទួលបាននូវជំនួយបច្ចេកទេស និងប្រឹក្សាយោបល់ក្នុងការរៀបចំ **«ទិវាជីវៈចម្រុះអន្តរជាតិ ២២ ឧសភា»** ឆ្នាំ២០១៨ សំដៅជំរុញអនុវត្តអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះឱ្យមានប្រសិទ្ធភាព
- រៀបចំ **«ទិវាជីវៈចម្រុះអន្តរជាតិ ២២ ឧសភា»** ឆ្នាំ២០១៨ នៅថ្នាក់ក្រោមជាតិ នៅតាមសាលារៀន វត្តអារាម ឬតាមទីតាំងសមស្របណាមួយ ក្នុងខេត្តប្រកបដោយភាពអធិកអធម និងជំរុញឱ្យមានការចូលរួមពីគ្រប់ស្ថាប័នពាក់ព័ន្ធ។

ក្នុងស្មារតីនេះ សូមអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរបរិស្ថានរាជធានី-ខេត្ត វិស័យឯកជន អង្គការ សង្គមស៊ីវិលដែលជាដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ សហគមន៍មូលដ្ឋាន និងគ្រប់អ្នកពាក់ព័ន្ធ មេត្តាចូលរួម សហការ និងអនុវត្តឱ្យបានជោគជ័យនូវស្មារតីនៃ **«ទិវាជីវៈចម្រុះអន្តរជាតិ ២២ ឧសភា»** ឆ្នាំ២០១៨នេះ។

ថ្ងៃ ព្រហស្បតិ៍ ៣កើត ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១៨

**ប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

**និងជារដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**